ខុមហ្វ្រែល COMFREL

គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌នៅកម្ពុជា (គ.ប.ស.យ)

Committee for Free and Fair Elections in Cambodia (COMFREL)

ទីស្នាក់ការកណ្តាល ផ្ទះលេខ ១៣៨ ផ្លូវ ១២២ សង្កាត់ទឹកល្អក់ ១ ខ័ណ្ឌទួលគោក រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
Central Office: #138, St. 122, Teuk Laak I, Tuol Kork, Phnom Penh, CAMBODIA.
P.O. Box 1145, Tel: (855) 23 884 150/12 942 019, Fax: (855) 23 883 750 E-mail: comfrel@online.com.kh, comfrel@comfrel.org or comfreladmin@online.com.kh, Site : www.comfrel.org

**គណៈកម្មាធិការនាយក**
**BOARD OF DIRECTORS**

1. លោក **ធុន សារាយ**
**Mr. THUN Saray**
ប្រធានគណៈកម្មាធិការនាយក
និងជាប្រធាន **ADHOC**

2. លោក **សុក សំអឿន**
**Mr. SOK Sam Oeun**
អនុប្រធានគណៈកម្មាធិការនាយក
និងជានាយក **CDP**

3. លោក **យឹម ប៉ូ**
**Mr. YIM Po** អគ្គហេរញ្ញិក
និងជានាយក **CCPCR**

4. អ្នកស្រី **ស៊ុន ចាន់សែន**
**Mrs. SUN Chansen** សមាជិកា
និងជាប្រធាន **KYA**

5. លោក **យង់ គិមអេង**
**Mr. YONG Kim Eng** សមាជិក
និងជានាយក **PDP-Center**

6. លោក **មុំ សារិន**
**Mr. MOM Sarin** សមាជិកា
និងជានាយក **HRCDO**

7. អ្នកស្រី **ទីវ សារាយេត**
**Ms. TIV Sarayet** សមាជិកា
និងជាសហនាយិកា **WMC**

8. កញ្ញា **សយ សារា វឌ្ឍនី**
**Miss. SAY Sara Vathany**
សមាជិកា
និងជានាយិកា **CWCC**

9. លោក **គីម សុវណ្ណ**
**Mr. KIM Sovann** សមាជិក
និងជានាយក **VIGILANCE**

10. នាយក **LAC (NA)**

11. នាយក **KKKHRO (NA)**

12. អ្នកស្រី **ពឹង យក់ហៀប**
**Ms. PEUNG Yok Hiep** សមាជិកា
ជាឥស្សរជន Dignitary

13. លោក **សឺន សែត**
**Mr. SEN Set** សមាជិក
ជាឥស្សរជន Dignitary

ស.ប្រ.ក.ព/លេខ ០៧/១០ គ.ប.ស.យ/អ.ក

# សេចក្តីប្រកាសព័ត៌មាន

# ស្តីពី

# លទ្ធផលវាយតម្លៃរបស់ម្ចាស់ឆ្នោតទៅលើការអនុវត្តន៍លក្ខខណ្ឌសន្ទស្សន៍នៃវិស័យអាទិភាព ក្នុងខេត្ត កំពត

*ភ្នំពេញ, ថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ២០១០*

ម្ចាស់ឆ្នោតនៅខេត្តកំពតប្រមាណ ១០០នាក់ ក្នុងនោះមាន ស្ត្រី ៣០នាក់ មកពីសហគមន៍ ព្រៃឈើ ដីធ្លី នេសាទ,,,,,,, អង្គការមិនមែនរដ្ឋាភិបាលនានា អាជីវករ/ពាណិជ្ជករ មន្ត្រីរាជការ សិស្ស/និស្សិត កសិករ ដែលមកពីគ្រប់ស្រុក និងក្រុងក្នុងខេត្តកំពត បានបង្ហាញពីការពេញចិត្តទៅលើការអនុវត្តការងាររបស់មន្ត្រីជាប់ឆ្នោតក្នុងការអនុវត្តន៍លក្ខខណ្ឌសន្ទស្សន៍នៃវិស័យអាទិភាពក្នុងខេត្តកំពត បើទោះបីជាចំនុចនៃលក្ខខណ្ឌសន្ទស្សន៍ភាគច្រើនមិនត្រូវបានអនុវត្ត ឬអនុវត្តបានតិចតួចក៏ដោយ។

ការវាយតំលៃរបស់ម្ចាស់ឆ្នោតទៅលើលក្ខខណ្ឌសន្ទស្សន៍នេះ ម្ចាស់ឆ្នោតភាគច្រើនវាយតំលៃថា មិនបានធ្វើទាល់តែសោះ ដូចជាការផ្តល់មេធាវីដល់ប្រជាពលរដ្ឋក្រីក្រដោយឥតគិតថ្លៃ ការចាត់វិធានការតាមផ្លូវច្បាប់ម៉ឺងម៉ាត់ដល់មន្ត្រីរដ្ឋបាលព្រៃឈើ កងកំលាំងប្រដាប់អាវុធ ការបញ្ចុះតំលៃសេវាទូរស័ព្ទ ការស្តារឡើងវិញនូវទំនប់ស្តុកទឹក បញ្ចុះតំលៃប្រេងសាំង និងម៉ាសូត និងសុំអោយយកអាត្រាការប្រាក់ទាបជាង ១%ក្នុងមួយខែ។

មិនមានលក្ខខណ្ឌសន្ទស្សន៍ណាមួយដែលត្រូវបានម្ចាស់ឆ្នោតភាគច្រើន ធ្វើការវាយតំលៃថា ត្រូវបានអនុវត្តទាំងស្រុង ឬអនុវត្តបានច្រើននោះទេ ។ ទោះបីយ៉ាងណាមានលក្ខខណ្ឌសន្ទស្សន៍មួយចំនួនដូចជាការជួសជុល និងស្តារប្រព័ន្ធធារាសាស្ត្រ ការបណ្តុះបណ្តាល និងបង្កើតទីផ្សារដល់កសិករ ការចុះបញ្ជីសហគមន៍នេសាទ ការបង្កើនប្រាក់បៀវត្សរ៍ដល់គ្រូបង្រៀន ព្រមទាំងការបង្កើតមជ្ឈមណ្ឌលអប់រំកែប្រែ និងបណ្តុះ បណ្តាលវិជ្ជាជីវៈ ត្រូវបានម្ចាស់ឆ្នោតភាគច្រើនធ្វើការវាយតំលៃថា កំពុងត្រូវបានអនុវត្តបានខ្លះៗ។

អ្នកតំណាងរាស្ត្រ **មូរ សុខហួរ** មណ្ឌលកំពត និងសមាជិកក្រុមប្រឹក្សាខេត្តកំពត ឯកឧត្តម **ឃុយ សៀន** ឯកឧត្តម **អ៊ុក សារុធ** និងលោក **ង៉ែត សារឿន** នាយអធិការកិច្ចសាលាខេត្តបានធ្វើការសន្យាថា នឹងពាំនាំសំលេងប្រជាពលរដ្ឋទៅថ្នាក់លើ និងស្ថាប័នពាក់ព័ន្ធដើម្បីអោយការអភិវឌ្ឍន៍មានភាពស្មើគ្នា។

ការវាយតម្លៃនេះ ម្ចាស់ឆ្នោតធ្វើការផ្តល់ពិន្ទុទៅលើការបំពេញ/សម្រេចបានទៅលើចំនុចនីមួយៗដែលម្ចាស់ឆ្នោតបានធ្វើការទាមទារកាលពីខែមេសា ឆ្នាំ២០០៩ ដោយឱ្យពិន្ទុ "ពិន្ទុ១ សំរាប់ការមិនបានធ្វើទាល់តែសោះ ឬបានធ្វើតិចតួច(ច្រើនបំផុតត្រឹម ២០%)" "ពិន្ទុ២ សំរាប់ការបានធ្វើខ្លះ (២១%-៤០%)" "ពិន្ទុ៣ សំរាប់ការបានធ្វើមធ្យម ឬបានធ្វើពាក់កណ្តាល (៤១%-៦០%)" "ពិន្ទុ៤ សំរាប់ការបានធ្វើច្រើន (៦១%-៨០%)" និង "ពិន្ទុ៥ សំរាប់ការបានធ្វើស្ទើរតែទាំងស្រុង ឬបានធ្វើទាំងស្រុង (៨១%-១០០%)"។

ជាលទ្ធផល ម្ចាស់ឆ្នោតបានផ្តល់ពិន្ទុទៅលើការសម្រេចបានរបស់មន្ត្រីជាប់ឆ្នោតទៅលើចំនុចនីមួយៗ ដែលម្ចាស់ឆ្នោតបានកំណត់កាលពីឆ្នាំ២០០៩ ដូចខាងក្រោម៖

| **លទ្ធផលនៃការវាយតម្លៃរបស់ម្ចាស់ឆ្នោតទៅលើការសម្រេចបាន របស់មន្ត្រីជាប់ឆ្នោតទៅលើចំនុចនីមួយៗនៃលក្ខខណ្ឌសន្ទស្សន៍នៃវិស័យអាទិភាពនាំងជប់នៅក្នុងខេត្តកំពត** |
|---|
| ១) ជួសជុល និងស្តារប្រព័ន្ធធារាសាស្ត្ររាល់មួយឆ្នាំម្តងក្នុងចំណោម ៧ ស្រុករួមមានស្រុកទឹកឈូរ ស្រុកឈូក ស្រុកដងទង់ ស្រុកកំពង់ត្រាច ស្រុកបន្ទាយមាស ស្រុកជុំគីរី និងស្រុកអង្គរជ័យ ចាប់ពីឆ្នាំ ២០០៩ ដល់ ២០១២ យ៉ាងយូរ ត្រូវស្តារអោយបានគ្រប់ស្រុក ។<br>ពិន្ទុ **១ (១០%)** ពិន្ទុ **២ (៤៣%)** ពិន្ទុ **៣ (៣៤%)** ពិន្ទុ **៤ (១០%)** ពិន្ទុ **៥ (៣%)** |
| ២) ផ្តល់ការបណ្តុះបណ្តាលទំនាក់ទំនងទីផ្សារ និងបង្កើតទីផ្សារ ដល់កសិករ ព្រមទាំងបង្កើនពន្ធការនាំចូលនូវ ផលិតផលកសិកម្ម (អោយលើសពីពន្ធបច្ចុប្បន្ន) ពីខាងក្រៅដែលខេត្តកំពតមាន (ស្រូវ បន្លែ ដូង ពោត..) ចាប់ពីឆ្នាំ ២០០៩ ដល់ ២០១២ ។<br>ពិន្ទុ **១ (៣៩%)** ពិន្ទុ **២ (៤០%)** ពិន្ទុ **៣ (១៥%)** ពិន្ទុ **៤ (៥%)** ពិន្ទុ **៥ (១%)** |
| ៣) ចាប់ពីឆ្នាំ ២០០៩ ទៅ អាជ្ញាធរជលផលត្រូវតែទទួលស្គាល់ និងចុះបញ្ជីសហគមន៍នេសាទរបស់ប្រជាពលរដ្ឋដែលបានបង្កើតឡើងដែលបានដាក់ពាក្យទៅ និងបង្ក្រាបបទល្មើសនេសាទទាំងអស់អោយបាន [១០០%] ។<br>ពិន្ទុ **១ (២៧%)** ពិន្ទុ **២ (៣១%)** ពិន្ទុ **៣ (២៩%)** ពិន្ទុ **៤ (១២%)** ពិន្ទុ **៥ (២%)** |
| ៤) ផ្តល់មេធាវីដល់ប្រជាពលរដ្ឋក្រីក្រដោយឥតគិតថ្លៃ ហើយ [តុលាការ]ស៊ើបអង្កេតរឿងក្តី និងបណ្តឹងអោយបានច្បាស់លាស់ដល់ទីកន្លែងគ្រប់ភាគី ដែលពាក់ព័ន្ធទាំងអស់នៅខេត្តកំពតចាប់ពីឆ្នាំ ២០១០តទៅ ។<br>ពិន្ទុ **១ (៧៦%)** ពិន្ទុ **២ (១៨%)** ពិន្ទុ **៣ (៥%)** ពិន្ទុ **៤ (១%)** ពិន្ទុ **៥ (0%)** |
| ៥) ចាត់វិធានការតាមផ្លូវច្បាប់ម៉ឺងម៉ាត់ដល់មន្ត្រីរដ្ឋបាលព្រៃឈើ កងកំលាំងប្រដាប់អាវុធ និងអ្នកមានអំណាចមួយចំនួនដែលឃុបឃិតជាមួយជនល្មើសកាប់បំផ្លាញព្រៃឈើដែលខុសច្បាប់ក្នុងខេត្តកំពត ចាប់ពីឆ្នាំ ២០០៩ តទៅ អោយបាន [១០០%] ។<br>ពិន្ទុ **១ (៤២%)** ពិន្ទុ **២ (២៧%)** ពិន្ទុ **៣ (១៩%)** ពិន្ទុ **៤ (១១%)** ពិន្ទុ **៥ (១%)** |
| ៦) តម្លៃសេវាទូរស័ព្ទ ការប្រើប្រាស់ប្រព័ន្ធនីមួយៗសូមបញ្ចុះតម្លៃទូរស័ព្ទត្រឹមតែ ៣ សេន ក្នុងមួយនាទី [ឆ្លងប្រព័ន្ធ] យ៉ាងយូរត្រឹមឆ្នាំ ២០១០ និងនៅគ្រប់សាលាស្រុកទាំងអស់ត្រូវមានប្រព័ន្ធអ៊ីនធឺណែតសំរាប់ប្រជាពលរដ្ឋប្រើប្រាស់ជាសាធារណៈដោយឥតគិតថ្លៃនៅស្រុកទាំង៧ និងក្រុងកំពត ខេត្តកំពត យ៉ាងយូរអោយបាននៅឆ្នាំ២០១១។<br>ពិន្ទុ **១ (៤៥%)** ពិន្ទុ **២ (២៤%)** ពិន្ទុ **៣ (១៨%)** ពិន្ទុ **៤ (៥%)** ពិន្ទុ **៥ (៧%)** |

៧) បង្កើនប្រាក់បៀវត្សរ៍ដល់គ្រូបង្រៀនឱ្យបានសមរម្យ គឺឱ្យបាន៤៥% ជារៀងរាល់ឆ្នាំដើម្បីពង្រឹងសមត្ថភាពគ្រូបង្រៀន។

ពិន្ទុ **១ (១៩%)** ពិន្ទុ **២ (៥២%)** ពិន្ទុ **៣ (២០%)** ពិន្ទុ **៤ (៣%)** ពិន្ទុ **៥ (៥%)**

៨) បង្កើតមជ្ឈមណ្ឌលសម្រាប់អប់រំកែប្រែអត្តចរឹត និងបណ្តុះបណ្តាលវិជ្ជាជីវៈ (កាត់ដេរ ជួសជុលម៉ូតូ....) សម្រាប់ក្មេង អនាថា និងយុវជនគ្មានការងារធ្វើនៅក្រុងកំពតដោយកសាងអាគារចំនួន ២ខ្នង (សម្រាប់ប្រមូលក្មេង និងយុវជនអនាថា) ឱ្យរួចរាល់ក្នុងឆ្នាំ ២០១២។

ពិន្ទុ **១ (១៣%)** ពិន្ទុ **២ (៤៤%)** ពិន្ទុ **៣ (២៨%)** ពិន្ទុ **៤ (៩%)** ពិន្ទុ **៥ (៥%)**

៩) ស្តារឡើងវិញនូវទំនប់ស្ទាក់ទឹក ឃុំ កោះតូច ស្រុកទឹកឈូ ខេត្ត កំពត ឆ្នាំ ២០០៩ ដល់ឆ្នាំ ២០១០ និងសូមបញ្ចុះតម្លៃប្រេងសាំងត្រឹមតែ ២000 រៀលក្នុងមួយលីត្រ និងប្រេងម៉ាសូតក្នុងតម្លៃង ១000 រៀលក្នុងមួយលីត្រ។

ពិន្ទុ **១ (៦០%)** ពិន្ទុ **២ (៣១%)** ពិន្ទុ **៣ (៤%)** ពិន្ទុ **៤ (២%)** ពិន្ទុ **៥ (២%)**

១០) គ្រប់ស្ថាប័នឥណទានត្រូវយកការប្រាក់ទាបជាង ១%ក្នុងមួយខែ និងត្រូវមានការបណ្តុះបណ្តាលដល់ប្រជាពលរដ្ឋពីការប្រើប្រាស់លុយកម្ចី មុននឹងអនុញ្ញាតខ្ចី ចាប់ពីឆ្នាំ ២០១០តទៅ។

ពិន្ទុ **១ (៤២%)** ពិន្ទុ **២ (៣៨%)** ពិន្ទុ **៣ (១៦%)** ពិន្ទុ **៤ (៤%)** ពិន្ទុ **៥ (១%)**

១១) **ចំនុចរួមៈ តើអ្នកពេញចិត្តការអនុវត្តរបស់មន្ត្រីជាប់ឆ្នោតទៅលើលក្ខខណ្ឌសន្ទស្សន៍ទាំង១០ កម្រិតណា?**

☐ ១) មិនពេញចិត្តទាល់តែសោះ, ☐២) ពេញចិត្តតិចតួច, ☐ ៣) ពេញចិត្តគួរសម, ☐៤) ពេញចិត្តច្រើន, ☐៥) ពេញចិត្តទាំងស្រុង

ពិន្ទុ **(៣%)** ពិន្ទុ **(១៨%)** ពិន្ទុ **(៣៣%)** ពិន្ទុ **(៣១%)** ពិន្ទុ **(១៦%)**

ការវាយតម្លៃនេះ ត្រូវបានធ្វើឡើងដោយម្ចាស់ឆ្នោតក្នុងវេទិកាម្ចាស់ឆ្នោតដែលរៀបចំដោយគណៈកម្មាធិការ **ខុមហ្វ្រែល** នៅថ្ងៃទី ០៩ ខែកក្កដា ឆ្នាំ២០១០នៅខេត្តកំពត ដោយមានកិច្ចសហការជាមួយសមាគមការពារសិទ្ធិមនុស្ស និងអភិវឌ្ឍន៍នៅកម្ពុជា (ADHOC) ក្រុមប្រឹក្សាយុវជនកម្ពុជា (YCC) និងមជ្ឈមណ្ឌលអភិវឌ្ឍន៍កុមារ និងស្ត្រីនៅកម្ពុជា (CWDCC) ។

*សម្រាប់ព័ត៌មានបន្ថែមៗសូមទាក់ទងៈ*

- លោក **សុខ ពិនុរ្យ** អ្នកសម្របសម្រួលផ្នែកអង្កេតខុមហ្វ្រែល ទូរស័ព្ទៈ ០៨៩ ៥២៥ ៤៤៦